ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្ថលេខានិងត្រា ហត្ថលេខានិងត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

* * *

## ២—សេចក្តីសំរេច

រាជធានីភ្នំពេញ ,ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៦

**សេចក្តីសំរេចលេខ ២៥ សសរ**

**ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួងសំរាប់ទទួល**

**បញ្ជូនជនភៀសខ្លួនខ្មែរ មកពីប្រទេសឥណ្ឌូនេស៊ី**

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– យោងតាមសំណូមពរការងារចាំបាច់

**សំរេច**

**ប្រការ ១** : បង្កើតក្រុមការងារអន្តរក្រសួងមួយ ដែលមានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| ១–តំណាងក្រសួងមហាផ្ទៃ | ប្រធាន |
| ២–តំណាងភាកបាទក្រហមកម្ពុជា | អនុប្រធាន |
| ៣–តំណាងក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន | សមាជិក |

៤–តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ　　សមាជិក

៥–តំណាងក្រសួងសុខាភិបាល　　សមាជិក

៦–មន្ត្រីក្រសួងមហាផ្ទៃ ចំនួន ០២ រូប　　សមាជិក

**ប្រការ ២** : ក្រុមការងារនេះមានភារកិច្ចដូចតទៅ ៖

–សហការជាមួយស្ថាប័នពាក់ព័ន្ធ ត្រៀមរៀបចំជំរំបណ្តោះអាសន្នមួយ សំរាប់ទទួលបងប្អូនជនភៀសខ្លួនខ្មែរចំនួន ៣១៨ នាក់ មកពីជំរំ ហ្គាឡង់ ប្រទេសឥណ្ឌូនេស៊ី ។

–លើកគំរោងថវិកា សំរាប់ចំណាយ

–កាកបាទក្រហមធ្វើការទំនាក់ទំនងជាមួយ UNHCR ដើម្បីសុំអោយ អង្គការនេះជួយ ឧបត្ថម្ភបងប្អូនជនភៀសខ្លួនខ្មែរទាំង ៣១៨ នាក់ រហូតដល់គោលដៅចុងក្រោយ ដែលមានទីតាំងរស់នៅលើទឹកដីកម្ពុជា ។

–លើកគំរោងសុំការសំរេចពីរាជរដ្ឋាភិបាល ក្នុងករណីដែលក្រុមការងារមិនអាចដោះស្រាយបាន ។

–រាយការណ៍អំពីលទ្ធផលការងារជូនទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៣** : សមាជិកក្រុមការងារទាំងអស់ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន កាកបាទក្រហមកម្ពុជា និងក្រសួងស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *